**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jan-2016, 14:10
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់លោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

# សំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកសារទូរលេខតាមផ្លូវទូតចំនួន ១១ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN
Xiaoyang NIE
Marina HAKKOU
Henri DECŒUR

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I- សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីការពារក្ដីរបស់លោក នួន ជា ("មេធាវីការពារក្ដី") សូមដាក់សំណើនេះ ("សំណើ") ស្នើសុំឱ្យទទួលយកឯកសារសារទូរលេខតាមផ្លូវទូតចំនួន ១១ ឯកសារជាឯកសារភស្តុតាងដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដោយក្នុងនោះមានឯកសារ ០២ បានមកពីស្ថានទូតអូស្ត្រាលីប្រចាំទីក្រុងហាណូយ, ឯកសារចំនួន ០៦ បានមកពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងបាងកក, ឯកសារចំនួន ០២ បានមកពីស្ថានទូតអាមេរិកប្រចាំទីក្រុងប៉ារីស និងឯកសារចំនួន ០១ បានមកពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញ ("សារទូរលេខតាមផ្លូវទូត")។

## II- ច្បាប់ជាធរមាន

2. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងអំឡុងពេលសវនាការ ភាគីមួយអាចស្នើសុំឱ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកការស្វែងរកការពិត" ដោយផ្អែកតាមខ្លឹមសារទូទៅដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងដែលចែងថា "ភស្តុតាង [...] ដែលត្រូវបានស្នើសុំនោះគឺមិនអាចរកបាននោះទេ មុនពេលបើកការជំនុំជម្រះ" ឬថា "មិនអាចរកបានពីមុនមក ទោះបីជាខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្ដី"[1]។ ដើម្បីបំពេញលក្ខខណ្ឌក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងដែលបានស្នើសុំនោះចាំបាច់ត្រូវតែភាពពាក់ព័ន្ធ និងអាចជឿទុកចិត្ត *ជាបឋម* តែប៉ុណ្ណោះ[2]។

## III- ទឡ្ហីករណ៍

3. ភស្តុតាងដែលបានស្នើសុំនោះ បំពេញគ្រប់តាមលក្ខខណ្ឌក្នុងការទទួលយកជាភស្តុតាង តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ភស្តុតាងនោះមិនអាចរកបាន មុនពេលបើកការជំនុំជម្រះ និង វាពាក់ព័ន្ធនឹងបញ្ហាដែលលើកឡើងក្នុងសំណុំរឿង ០០២/០២។

### ក. សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី

---

[1] **E313**, 'សាលក្រមសំណុំរឿង ០០២/០១', ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។

[2] ដូចខាងលើ កថាខណ្ឌ ២៦។

4. ឯកសារពីរដំបូងនៃភ័ស្តុតាង ដែលមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះទទួលយក គឺជាសារទូរលេខតាមផ្លូវទូតជាសារធារណៈ ដែលបានផ្ញើដោយស្ថានទូតអូស្ត្រាលីប្រចាំទីក្រុងហាណូយ ទៅក្រសួងការបរទេសអូស្ត្រាលី នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ និង ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ (**ភ្ជាប់មកជាមួយជាឯកសារសារធារណៈ ១ និង ២**)។

5. នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ សារព័ត៌មានកម្ពុជាឈ្មោះ *ខីមបូឌា ដេលី* បានចេញផ្សាយអត្ថបទមួយ ដោយដកស្រង់ភាគច្រើនចេញពីសារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី ដែលពាក់ព័ន្ធនឹងអំឡុងពេលពីរបីខែនៅក្រោយការរំដោះទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥[3]។ យោងតាមអត្ថបទនោះ សារទូរលេខតាមផ្លូវទូតនោះត្រូវបាន “Julio Jeldres ដែលជាអ្នកនិពន្ធជីវប្រវត្តិផ្លូវការរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ បានបរិច្ចាគទៅមជ្ឈមណ្ឌលឯកសារកម្ពុជា” នៅខែ កញ្ញា ឆ្នាំ ២០១៥។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានទទួលឯកសារស្កែននៃសារទូរលេខតាមផ្លូវទូតច្បាប់ដើម ពី វ៉ាន់ថាន់ ពៅតារា ជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

6. សារទូរលេខតាមផ្លូវទូតទីមួយ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ ពិពណ៌នា“សញ្ញាណប្រេះឆា” នៃទំនាក់ទំនងគ្នារវាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និង GRUNK ដោយរៀបរាប់អំពីការវាយប្រហាររបស់កងកម្លាំងវៀតកុង ទៅលើក្បួនរថយន្តដឹកគ្រឿងសម្ភារៈផ្គត់ផ្គង់របស់ខ្មែរក្រហម នៅក្បែរព្រំដែនវៀតណាម ក្នុងខែ កុម្ភៈ ឬ មីនា ឆ្នាំ ១៩៧៥[4]។ មិនតែប៉ុណ្ណោះ សារទូរលេខផ្លូវទូតនោះ លើកឡើងអំពី“ការតស៊ូយ៉ាងស្វិតស្វាញរបស់វៀតណាម ដើម្បីពង្រឹងឥទ្ធិពលវៀតណាមមកលើកម្ពុជា” នៅក្រោយការដួលរលំទីក្រុងភ្នំពេញ ដោយគូសបញ្ជាក់ថា “ថ្នាក់ដឹកនាំ [នៃរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម] ទំនងជាតាមឃ្លាំមើលយ៉ាងប្រយ័ត្នប្រយែងចំពោះការប្រជែងដែលអាចកើតមាន ដែលធ្វើឱ្យប៉ះពាល់ដល់ឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់”[5]។

7. សារទូរលេខតាមផ្លូវទូតទីពីរ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ ពិពណ៌នាអំពី “បញ្ហាព្រំដែន”

---

[3] Alex Willemyns, ‘សារទូរលេខតាមផ្លូវទូត និយាយលម្អិតអំពីបញ្ហាចិន-វៀតណាម នៅប្រទេសកម្ពុជាឆ្នាំ ១៩៧៥’, *Cambodian Daily*, ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។

[4] សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី ស្ថានទូតហាណូយ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៦។

[5] ដូចខាងលើ កថាខណ្ឌ ៥ និង ៩។

រវាងកម្ពុជា និងវៀតណាម ដោយរៀបរាប់អំពីការដណ្តើមកាន់កាប់កោះជាច្រើនដែលមានជម្លោះ ដោយកងកម្លាំងប្រដាប់អាវុធនៃរដ្ឋទាំងពីរ[6]។ ដោយយោងទៅ "ទស្សនៈដែលមានការដឹងឮទូទៅ ដែលថា បក្សពលករវៀតណាមយល់អំពីកម្ពុជា [...] ឬ យ៉ាងហោចណាស់ក៏ខ្លួនបានខិតខំធ្វើដូច្នេះ" សារទូរលេខតាមផ្លូវទូតនេះលើកឡើងផងដែរអំពី "ឥទ្ធិពលរបស់វៀតណាមមកលើកម្ពុជា" និង គូសបញ្ជាក់អំពី "មហិច្ឆិតាគួរឲ្យសង្ស័យរបស់វៀតណាមក្នុងការបង្កើត "សហព័ន្ធឥណ្ឌូចិន"" ដោយបានសន្និដ្ឋានថា "មហិច្ឆិតារបស់វៀតណាមទាំងអស់នេះ ពិតជាមានមែន"[7]។ នៅចុងបញ្ចប់ សារទូរលេខនោះយោងទៅរកអត្ថិភាពនៃ"ក្រុម"ជាច្រើន និង "មានបក្សផ្សេងៗនៅក្នុងចំណោមថ្នាក់ដឹកនាំកម្ពុជាដែលមានជម្លោះនឹងគ្នា"[8]។

*(i)* ***សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលីមិនអាចរកបាន នៅមុនពេលបើកការជំនុំជម្រះ***

8. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ចាប់ផ្តើមឡើង នៅខែ មិថុនា ឆ្នាំ ២០១១[9]។ ទោះបីជាសារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី ចុះកាលបរិច្ឆេទក្នុង អំឡុងពេលចាប់ពីខែ ឧសភា-សីហា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏វាពុំមែនជាការសមហេតុសមផលទេ ដែលរំពឹងឲ្យមេធាវីការពារក្តីអាចកំណត់អត្តសញ្ញាណភស្តុតាងនេះ ឲ្យបាននៅមុនពេលបើកការ ជំនុំជម្រះ។

9. មេធាវីការពារក្តី ទើបតែបានដឹងអំពីអត្ថិភាពនៃសារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលីនេះ តាមរយៈអត្ថបទសារព័ត៌មានដែលចេញផ្សាយដោយកាសែត *ឌឹខែមបូឌា ដេលី* កាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥[10]។ យោងតាមអត្ថបទនេះ សារទូរលេខតាមផ្លូវទូតទាំងនេះត្រូវបាន "ចាត់ទុកជា

---

[6] សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី ស្ថានទូតហាណូយ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៥ និង ៦។

[7] ដូចខាងលើ កថាខណ្ឌ ១១, ១២ និង ១៤។

[8] ដូចខាងលើ កថាខណ្ឌ ៧។

[9] **E307/1**, 'សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)', ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ **E307/1/2**, 'សេចក្តីសម្រេចលើសំណើរួមសុំឲ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[10] Alex Willemyns, 'សារទូរលេខតាមផ្លូវទូត និយាយលម្អិតអំពីបញ្ហាចិន-វៀតណាម នៅប្រទេសកម្ពុជាឆ្នាំ ១៩៧៥', *The Cambodia Daily*, ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។

ឯកសារសាធារណៈ នៅក្នុងឆ្នាំ ២០១១” និង “ត្រូវបានបរិច្ចាគទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយ Julio Jeldres ដែលជាអ្នកនិពន្ធជីវប្រវត្តិផ្លូវការរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ” កាលពីខែ កញ្ញា ឆ្នាំ ២០១៥។ នៅក្រោយការចេញផ្សាយអត្ថបទនេះភ្លាម មេធាវីការពារក្ដីបាន ស្នើទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសុំឯកសារស្កេនពីសារទូរលេខតាមផ្លូវទូតច្បាប់ដើម។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ វ៉ាន់ថាន់ ពៅតារា ដែលជានាយករងនៃមជ្ឈមណ្ឌលឯកសារ កម្ពុជាបានប្រគល់ឯកសារនោះមកមេធាវីការពារក្ដី។

10. នៅមុនការចេញផ្សាយអត្ថបទនេះ មេធាវីការពារក្ដីគ្មានមធ្យោបាយអ្វីក្នុងការដឹងថា រដ្ឋាភិបាល អូស្ត្រាលីមានតម្កល់ទុកព័ត៌មាន ដែលពាក់ព័ន្ធនឹងបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងសំណុំរឿង ០០២/០២។ ដោយពិចារណាទៅលើភាពកម្រនៃប្រភពធនធាន ក្នុងការដែលមេធាវីការពារក្ដីអាច រកបាន តាមតថភាពជាក់ស្ដែង គេមិនគួររំពឹងឲ្យមេធាវីការពារក្ដីធ្វើការទាក់ទងទៅផ្នែកកិច្ចការ ការទូតនៃគ្រប់ប្រទេសទាំង ១៩៣ ដែលជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ដោយសង្ឃឹមថា រដ្ឋទាំងនោះនឹងយល់ព្រមផ្ដល់រាល់ឯកសារពាក់ព័ន្ធដែលពួកគេមានទាំងអស់នោះបាននោះទេ ដ្បិត ឯកសារបែបនេះអាចស្ថិតនៅជាឯកសារសម្ងាត់នៅឡើយ តាមច្បាប់ការទូតនៃរដ្ឋនីមួយៗ។

11. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សារទូរលេខតាមផ្លូវទូតដែលត្រូវធ្វើឡើង និងត្រូវបាន ចាត់ថ្នាក់ជាឯកសារសាធារណៈ នៅមុនពេលចាប់បើកការជំនុំជម្រះ និងនៅពេលក្រោយមកទៀត ឯកសារនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈប្រព័ន្ធគេហទំព័រ WikiLeaks “មិនអាច រកបានពីមុនមក ទោះបីជាខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្ដី” និងថា អង្គជំនុំជម្រះរកឃើញ ថា ភាគីបានបំពេញគ្រប់លក្ខខណ្ឌ ដែលថាភាគីដែលបានស្នើសុំឲ្យទទួលយកភ័ស្តុតាងនោះបាន ខិតខំប្រឹងប្រែងសមហេតុផល ក្នុងការស្វែងរកឯកសារទាំងនោះ និងបានដាក់សំណើសុំ ដែលពាក់ព័ន្ធ ទៅតាមកាលកំណត់សមស្របមួយ[11]។ ដូច្នេះ គ្មានហេតុផលណាមួយ ដែលមាន

---

[11] **E282/2**, ‘សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និង ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្ដីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក (ឯកសារ E282 និង E282/1; E290 និង E290/1)’, ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ សូមមើលផងដែរ ព្រះរាអាជ្ញា ទល់នឹង *Taylor*, សំណុំរឿងលេខ SCSL-03-01, ‘សេចក្ដីសម្រេច លើសំណើជាបន្ទាន់ និង ជាសាធារណៈរបស់មេធាវីការពារក្ដី ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ A-C ដើម្បីបើកសំណុំរឿងរបស់ខ្លួនសាជាថ្មី ដើម្បីស្នើសុំទទួលយកឯកសារពាក់ព័ន្ធនឹងទំនាក់ទំនងរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និង ខាងផ្នែកព្រះរាជអាជ្ញាក្នុងការ ចោទប្រកាន់ Charles Taylor’, ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១ ទំព័រទី ៥, 10th recital។

ការអនុវត្តឲ្យប្រាសចាកពីគោលការណ៍ដែលកំពុងអនុវត្តនៅក្នុងករណីបច្ចុប្បន្ននោះទេ។

12. មេធាវីការពារក្តីពិតជាមិនអាចរកឃើញសារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលីនេះបានទេ មិនថាខ្លួនខិតខំប្រឹងប្រែងសមផលយ៉ាងណាក៏ដោយ ប្រសិនបើគ្មានដំណឹងអំពីអត្ថិភាពនៃឯកសារនេះកាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ នោះ។ ក្រោយពីបានទទួលដំណឹងអំពីការចេញផ្សាយឯកសារនេះភ្លាម មេធាវីការពារក្តីចាត់វិធានការ ដើម្បីបានទទួលឯកសារនេះភ្លាមៗ ដោយឥតបង្អង់យូរឡើយ។ ដូច្នេះ សារទូរលេខតាមផ្លូវទូតទាំងនេះ ត្រូវចាត់ទុកថាជាឯកសារដែលមិនអាចរកបាននៅមុនបើកការជំនុំជម្រះ មិនថាមានការខិតខំប្រឹងប្រែងសមហេតុផលក្នុងការរកវាយ៉ាងណាក៏ដោយ។ ឯកសារទាំងនេះ អាចទទួលយកបាន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

### *(ii) សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២*

13. សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលីរម្លឹកឡើងវិញនូវឧបត្តិហេតុជាច្រើន ដែលពាក់ព័ន្ធនឹងកងកម្លាំងប្រដាប់អាវុធ FUNK និងកងកម្លាំងដែលជាបណ្តាញរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និង យោងទៅលើមហិច្ឆិតា និងឥទ្ធិពលវៀតណាមនៅក្នុងទឹកដីកម្ពុជា។ ព័ត៌មាននេះពាក់ព័ន្ធនឹងផ្នែកមួយចំនួននៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងអត្ថិភាព និង លក្ខណៈនៃជម្លោះប្រដាប់អាវុធ[12]។ វាកបង្ហាញផងដែរអំពីការបោសសម្អាតផ្ទៃក្នុង[13] ដែលមានបុគ្គលជាច្រើននាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស២១ ដែលត្រូវបានសង្ស័យថា មានការចូលរួមក្នុងជម្លោះប្រដាប់អាវុធដោយមប្រើដល់ផលប្រយោជន៍ប្រទេសវៀតណាម។ ព័ត៌មាននេះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និង ជាពិសេសពាក់ព័ន្ធនឹងផ្នែកទី ៤ (“មន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង”)[14] និងផ្នែកទី៦ (“លក្ខណៈនៃជម្លោះប្រដាប់អាវុធ”)[15]។

---

[12] **D427**, ‘ដីកាដំណោះស្រាយ’, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៥០-១៥៥។

[13] ដូចខាងលើ កថាខណ្ឌ ១៩២ ដល់ ២០៣ និង ៤១៥ ដល់ ៤៧៥។

[14] សូមមើលឯកសារ **E315** “សេចក្តីសម្រេចអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២” ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៤ កថាខណ្ឌ ១៤(ឃ)(គ)។

[15] *សូមមើល* **E315**, ‘សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ (‘សេចក្តីសម្រេចស្តីពីលំដាប់លំដោយ’), កថាខណ្ឌ ១៤(ច)។

14. ជាងនេះទៀត នៅក្នុងសារទូរលេខតាមផ្លូវទូតទីពីរ ការយោងទៅអត្ថិភាពនៃ"ក្រុម"ជាច្រើន និង "បក្សផ្សេងៗនៅក្នុងចំណោមថ្នាក់ដឹកនាំកម្ពុជាដែលមានជម្លោះគ្នា"[16] ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងយោធា[17]។ ព័ត៌មាននេះពាក់ព័ន្ធគ្នាផងដែរទៅនឹងសមាសភាពនៃសហឧក្រិដ្ឋកម្ម[18] និងអំណាច និងការគ្រប់គ្រងរបស់ នួន ជា លើកម្មាភិបាល ប.ក.ក[19] និង ពាក់ព័ន្ធការទទួលខុសត្រូវរបស់គាត់ក្នុងការបញ្ជា[20] ញុះញង់[21] និងក្នុងនាមគាត់ជាថ្នាក់លើ[22]។ ព័ត៌មាននេះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ទាំងមូល និងពាក់ព័ន្ធទៅនឹងផ្នែកចុងក្រោយអំពី ("តួនាទីជនជាប់ចោទ")[23]។

*(iii) សារទូរលេខតាមផ្លូវទូតរបស់អូស្ត្រាលី គួរឱ្យជឿទុកចិត្ត*

15. យថាភាព នៃសារទូរលេខតាមផ្លូវការទូតរបស់អូស្ត្រាលី មានលក្ខណៈច្បាស់លាស់។ ឯកសារដែលភ្ជាប់មកជាមួយសំណើនេះ ត្រូវបានស្កេនចេញពីសារទូរលេខតាមផ្លូវទូតច្បាប់ដើម ដែលបង្ហាញអត្ថបទវាយដោយអង្គុលីលេខ និងមានស្លាកសញ្ញាសម្គាល់រដ្ឋាភិបាលអូស្ត្រាលី តែមផ្លូវការរបស់ក្រសួងការបរទេសអូស្ត្រាលី ដោយគូសបញ្ជាក់ថ្ងៃដាក់ឯកសារ និងកម្រិតនៃការចាត់ចំណាត់ថ្នាក់ឯកសារ ហត្ថលេខាដោយដៃរបស់ម្ចាស់អត្ថបទ និង មានកំណត់សម្គាល់សរសេរដោយដៃផ្សេងៗទៀត។

**ខ. សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក**

16. ឯកសារទី ៣ ក្នុងចំណោមឯកសារទាំង ១១ ដែលមេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយក គឺជាសារទូរលេខតាមផ្លូវការទូតរបស់សហរដ្ឋអាមេរិកចំនួន ៩ ឯកសារ។ សារទូរលេខតាមផ្លូវទូត ៨ ដំបូងគឺជាឯកសារដែលធ្វើឡើងភ្លាមៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនោះត្រូវបានផ្ញើដោយស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងបាងកក និង ប៉ារីស ទៅ

---

[16] *សូមមើល* កថាខណ្ឌ ៧ ខាងលើ។

[17] **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ៣៣-៦៣ និង ១១៣-១៤៩។

[18] ដូចខាងលើ កថាខណ្ឌ ១៥៩ និង ១៥២៩។

[19] ដូចខាងលើ កថាខណ្ឌ ៨៧០, ៨៧៦, ៨៨០, ៨៨១, ៨៨២, ៨៨៤, ៨៩១, ៩១៣, ៩៦០, ១៥៣២, និងកថាខណ្ឌផ្សេងទៀត។

[20] ដូចខាងលើ កថាខណ្ឌ ១៥៥៣–១៥៥៤។

[21] ដូចខាងលើ កថាខណ្ឌ ១៥៤៧–១៥៤៨។

[22] ដូចខាងលើ កថាខណ្ឌ ១៥៥៨–១៥៦០។

[23] *សូមមើល* **E315**, សេចក្ដីសម្រេចស្ដីពីលំដាប់លំដោយ, កថាខណ្ឌ ១៤(ធ)។

កាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក នៅចន្លោះឆ្នាំ ១៩៧៦ និង ១៩៧៨។ សារទូរលេខតាមផ្លូវទូតទាំងអស់នេះ ជាផ្នែកមួយនៃសំណុំឯកសារជាច្រើន ដែលត្រូវបានចាត់ថាជាឯកសារសាធារណៈដោយក្រសួងការបរទេសអាមេរិក នៅក្នុងពេលដែលខ្លួនពិនិត្យឡើងវិញជាប្រព័ន្ធលើឯកសារដែលត្រូវបានចាត់ថ្នាក់ថាជាឯកសារសម្ងាត់ និងត្រូវបានផ្សព្វផ្សាយដោយរដ្ឋបាលបណ្ណាសារដ្ឋាន និងកំណត់ហេតុជាតិនៃសហរដ្ឋអាមេរិក[24]។ កាលបរិច្ឆេទនៃការចាត់ឯកសារនេះថាជាឯកសារសាធារណៈ ត្រូវបានសរសេរនៅលើផ្នែកក្បាលទំព័រ និងជើងទំព័រនៅរាល់ទំព័រនៃសារទូរលេខតាមផ្លូវទូត។ សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកចំនួន ០៣ ត្រូវបានចាត់ថាជាឯកសារសារធារណៈ និងផ្សព្វផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦។ ឯកសារមួយចេញផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ និងឯកសារ ០៤ ចេញផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។ ក្រោយៗមកទៀត សារទូរលេខទាំងនេះត្រូវបានបោះពុម្ពផ្សាយដោយអង្គការមិនរកប្រាក់កម្រៃមួយឈ្មោះ WikiLeaks។ WikiLeaks បានចេញផ្សាយកម្រងសារទូរលេខផ្នែកការទូតសហរដ្ឋអាមេរិកជាច្រើន។ កម្រងសារទូរលេខតាមផ្លូវទូតដំបូងមានឈ្មោះថា "សារទូរលេខតាមផ្លូវទូត Kissinger" ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ១៩៧៣ ដល់ ១៩៧៦ និងត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣[25]។ កម្រងសារទូរលេខតាមផ្លូវទូតទីពីរមានឈ្មោះថា "សារទូរលេខតាមផ្លូវទូត Carter" ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ១៩៧៧ និងត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[26]។ កម្រងសារទូរលេខតាមផ្លូវទូតទីបីមានឈ្មោះថា "សារទូរលេខតាមផ្លូវទូត Carter II" ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ១៩៧៨ និងត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥[27]។ សារទូរលេខទីប្រាំបួន និងចុងក្រោយ ចុះកាលបរិច្ឆេទចាប់ពីឆ្នាំ ២០០២ និងត្រូវបានផ្សព្វផ្សាយដោយ WikiLeaks ជាផ្នែកមួយនៃការផ្សព្វផ្សាយ "កម្រងសារទូរលេខតាមផ្លូវទូត" នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១។

---

[24] មូលដ្ឋានទិន្នន័យតាមបណ្តាញអ៊ិនធើណិតរបស់បណ្ណាសារដ្ឋានជាតិ អាចរកបាននៅ https://aad.archives.gov/aad/។

[25] WikiLeaks, 'WikiLeaks គម្រោងពិសេស K៖ សារទូរលេខតាមផ្លូវទូតរបស់ Kissinger', ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣, អាចរកបាននៅតាមអ៊ិនធើណិតតាមគេហទំព័រ https://wikileaks.org/។

[26] WikiLeaks, 'WikiLeaks ការផ្សព្វផ្សាយសារទូរលេខតាមផ្លូវទូតរបស់ Carter', ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, អាចរកបាននៅតាមអ៊ិនធើណិតតាមគេហទំព័រ https://wikileaks.org/WikiLeaks-releases-the-Carter.html។

[27] WikiLeaks, 'WikiLeaks បញ្ចេញសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិកពីឆ្នាំ ១៩៧៨ ជាងកន្លះលានឯកសារ', ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ អាចរកបានតាមអ៊ិនធើណិតតាមគេហទំព័រ https://wikileaks.org/plusd/pressrelease/។

17. សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ និងមានចំណងជើងថា "ភាពងាយរងគ្រោះនៃរបបភ្នំពេញ" ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកកទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកលេខ ១" ដែលភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៣**)[28]។ សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកលេខ ១ ត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និង ត្រូវបានផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥។ ឯកសារនេះពិពណ៌នាអំពី "សញ្ញាណប្រេះឆា" នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដោយពិភាក្សាអំពីជម្លោះកម្ពុជាជាមួយនឹងវៀតណាម និងស្ថានភាពតានតឹងយ៉ាងខ្លាំងខាងផ្ទៃក្នុងរវាងអាជ្ញាកម្ពុជាប្រជាធិបតេយ្យនៅភ្នំពេញ និងមេបញ្ជាការតំបន់។ សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកលេខ ១ រម្លឹកអំពី "ការវាយប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ" និង "ការរបួស និងស្លាប់យ៉ាងច្រើន" នៅក្នុង "សង្គ្រាមតាមព្រំដែនជាមួយវៀតណាម" ដោយកត់សម្គាល់នូវ "ការប្តេជ្ញាយ៉ាងមុតមាំរបស់វៀតណាម ក្នុងការទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយការផ្តុំកម្លាំងចូលគ្នាយ៉ាងធំមួយ ឬការធ្វើវិទ្ធង្សនា"[29]។ ឯកសារនេះគូសបញ្ជាក់ផងដែរនូវអត្ថិភាពនៃ "ការតស៊ូដែលនៅសេសសល់បន្តិចបន្តួច ដែលប្រហែលជាដឹកនាំដោយខ្មែរដែលធ្លាប់ហ្វឹកហ្វឺននៅវៀតណាម[30]" និងលើកឡើងអំពីតួនាទី សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា ក្នុង "ការដឹកនាំការវាយប្រយុទ្ធនៅប៉ែកខាងកើតនៃប្រទេសកម្ពុជា ដើម្បីប្រឆាំងតទល់នឹង ប៉ុល ពត"[31]។ ឯកសារនេះព្យាករណ៍ "ជោគជ័យ ជាបន្តបន្ទាប់ពីចលនាតស៊ូដែលគាំទ្រដោយទីក្រុងហាណូយនៅកម្ពុជាប៉ែកខាងកើតនៃប្រទេសកម្ពុជា" ដោយលើកឡើងអំពីលទ្ធភាពនៃការបះបោររបស់មេបញ្ជាការតាមតំបន់ជាពិសេសនៅភូមិភាគបូព៌ាដែលដឹកនាំដោយ សោ ភឹម និងរៀបរាប់អំពី"អស្ថិរភាព [...] នាំទៅដល់ការបោសសម្អាត" កាលពីអតីតកាលនៅក្នុងតំបន់ប៉ែកខាងបស្ចិមនៃប្រទេស[32]។

18. សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកទីពីរ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងមានចំណង

---

[28] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក 'ភាពងាយរងគ្រោះនៃរបបភ្នំពេញ', ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ BANGKO 23954។

[29] ដូចខាងលើ កថាខណ្ឌ ១។

[30] ដូចខាងលើ កថាខណ្ឌ ៤។

[31] ដូចខាងលើ កថាខណ្ឌ ៧។

[32] ដូចខាងលើ កថាខណ្ឌ ៨។ សូមមើលផងដែរសេចក្តីសង្ខេប។

ជើងថា "ការវាយប្រហារបន្ថែមទៀតនៅតាមព្រំដែនថៃ" ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក ទៅកាន់រដ្ឋមន្ត្រីការបរទេសអាមេរិក ("សារទូរលេខការទូតអាមេរិកទីពីរ" ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៤**)[33]។ សារទូរលេខការទូតអាមេរិកទីពីរនេះ ត្រូវបានចាត់ទុកជាឯកសារសាធារណៈនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និងផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥។ ឯកសារនេះរាយការណ៍អំពីការប៉ះទង្គិចគ្នានៅតាមព្រំដែនដែលពាក់ព័ន្ធនឹង "ក្រុមឧទ្ទាមកុម្មុនីស្តខ្មែរក្រហម និងថៃ" និងបណ្តាលឲ្យមាន"របួស និងស្លាប់យ៉ាងច្រើន"[34] និងបានចោទសួរអំពី "សមត្ថភាពរបស់ភ្នំពេញក្នុងការគ្រប់គ្រងកងកម្លាំងតាមព្រំដែនរបស់ខ្លួន" និងសង្ស័យលើ "ទំនាស់រវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងខ្មែរតស៊ូ"[35]។

19. សារទូរលេខតាមផ្លូវទូតអាមេរិកទីបី ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងមានចំណងជើងថា "ចលនាតស៊ូរបស់ខ្មែរ និងលាវ៖ យុទ្ធនាការជ្រើសរើសកងកម្លាំង [*sic*] នៅប្រទេសថៃ" ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៣" ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៥**)[36]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៣ ត្រូវបានចាត់ថ្នាក់ជាឯកសារសារធារណៈនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និងផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥។ ឯកសារនេះគូសបញ្ជាក់អំពីកំណើននៃការកសាងកម្លាំងតស៊ូពីជំរំជនភៀសខ្លួននៅប្រទេសថៃ[37] និងផ្សាយបន្តរបាយការណ៍នៃការវាយប្រយុទ្ធដោយប្រដាប់អាវុធចូលក្នុងទឹកដីកម្ពុជា ដែលធ្វើឡើងដោយចលនា"ខ្មែរសេរី"[38]។

20. សារទូរលេខតាមផ្លូវទូតសហរដ្ឋអាមេរិកទីបួន ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងមានចំណងជើងថា "ទំនាក់ទំនងថៃ-ខ្មែរ៖ Fonman Uppadit ធ្វើទស្សនកិច្ចទៅកាន់ទីក្រុងភ្នំពេញ" ត្រូវបានផ្ញើ

---

[33] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក 'ការវាយប្រហារបន្ថែមទៀតរបស់ខ្មែរនៅព្រំដែនថៃ', ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ BANGKO 04791។

[34] ដូចខាងលើ កថាខណ្ឌ ១។

[35] ដូចខាងលើ កថាខណ្ឌ ៣។

[36] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក 'ចលនាតស៊ូកម្ពុជា និង លាវ៖ ការកសាងកម្លាំង [*sic*] យុទ្ធនាការនៅប្រទេសថៃ', ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ BANGKO 04575។

[37] ដូចខាងលើ កថាខណ្ឌ ១។

[38] ដូចខាងលើ កថាខណ្ឌ ១, ៣, និង ៥។

ចេញដោយស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៤" ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៦**)[39]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៤ នេះត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ និងផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥។ ឯកសារនេះពាក់ព័ន្ធនឹងកិច្ចប្រជុំការទូតជាន់ខ្ពស់រវាងថៃ និងកម្ពុជា នៅទីក្រុងភ្នំពេញ ដែលដោះស្រាយបញ្ហានៃព្រឹត្តិការណ៍ប៉ះទង្គិចគ្នាឡើងវិញតាមព្រំដែនរវាងប្រទេសទាំងពីរ។ បើតាមសារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៤ នេះ គណៈប្រតិភូកម្ពុជា ដឹកនាំដោយ ប៉ុល ពត និង អៀង សារី បានគូសបញ្ជាក់ថា ប្រទេសកម្ពុជា "រងការវាយប្រហារពីវៀតណាមចាប់តាំងពីដើម ឆ្នាំ ១៩៧៥" និងយល់ឃើញថា វៀតណាមកំពុងតែគាំទ្រអង្គការកុម្មុយនីស្តថៃមួយ ដែលកំពុងសកម្មនៅក្នុងទឹកដីកម្ពុជា"[40]។ ម្ចាស់សារទូរលេខនេះ បានសម្តែងចំណាប់អារម្មណ៍ចំពោះព័ត៌មាននេះ និងគូសបញ្ជាក់អំពី "ភាពទរសើបបំផុត"នៃព័ត៌មាននេះ[41]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៤ នេះក៏រៀបរាប់ផងដែរអំពីសកម្មភាពនៃចលនាតស៊ូ"ខ្មែរសេរី" ដែលធ្វើប្រតិបត្តិការនៅតាមព្រំដែនថៃ-កម្ពុជា[42]។

21. សារទូរលេខតាមផ្លូវទូតអាមេរិកទីប្រាំ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៧ និងមានចំណងជើងថា "កម្ពុជា-កិច្ចសន្ទនាគ្នាជាមួយចលនាតស៊ូ" ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកក ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥" ភ្ជាប់មកជាមួយជា**ឯកសារធារណៈលេខ ៧**)[43]។ សារទូរលេខតាមផ្លូវទូតលេខ ៥ ត្រូវបានចាត់ជាឯកសារសាធារណៈនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៩ និង ផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។ ឯកសារនេះពាក់ព័ន្ធនឹងកិច្ចពិភាក្សាគ្នារវាងមន្ត្រីទូតអាមេរិក និងមេដឹកនាំចលនាតស៊ូខ្មែរ ដែលមានមូលដ្ឋាននៅប្រទេសថៃ។ សារទូរលេខតាមផ្លូវទូតអាមេរិក

---

[39] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក 'ទំនាក់ទំនងថៃ-កម្ពុជា៖ Fonman Uppadit ធ្វើទស្សនកិច្ចទៅកាន់ភ្នំពេញ', ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៨, BANGKO 03886។

[40] ដូចខាងលើ កថាខណ្ឌ ១-២, និង ៩។

[41] ដូចខាងលើ កថាខណ្ឌ ២ និង ៥។

[42] ដូចខាងលើ កថាខណ្ឌ ៣។

[43] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក 'កម្ពុជា– ការសន្ទនាគ្នាជាមួយចលនាតស៊ូ', ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៧, BANGKO 21997។

លេខ ៥ នេះរាយការណ៍អំពីសកម្មភាពនៃក្រុមប្រដាប់អាវុធជាច្រើន ដែលធ្វើប្រតិបត្តិការនៅក្នុងទឹកដីកម្ពុជា ដូចជាការវាយប្រហារម្តងម្កាលមកលើក្បួនរថយន្តរបស់ខ្មែរក្រហម ដែលធ្វើឡើងដោយកម្លាំងដែលមានគ្នា ៤០០ នាក់នៅខេត្តកំពង់ស្ពឺ[44] និងការបំផ្លិចបំផ្លាញស្ពានដោយកម្លាំងតស៊ូដែលមានក្រុមផ្តាច់ខ្លួនខ្មែរក្រហមនៅក្នុងតំបន់នៃខេត្តកោះកុង និងពោធិ៍សាត់[45]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥ នេះក៏មានរៀបរាប់ផងដែរអំពី "ទំនាក់ទំនងជារចនាសម្ព័ន្ធរវាងចលនាតស៊ូ និងកងទ័ពថៃ" ដោយលើកឡើងអំពី "ហិរញ្ញប្បទានរបស់ចលនាតស៊ូកម្ពុជា" ដោយអតីតឧបនាយករដ្ឋមន្ត្រីថៃ[46]។ ជាចុងក្រោយ សារទូរលេខនេះលើកឡើងអំពី "ការតស៊ូក្នុងជួរថ្នាក់ដឹកនាំបច្ចុប្បន្ន"នៅក្នុង ប.ក.ក ទាក់ទងនឹង "ផែនការរដ្ឋប្រហារ"មួយ ពាក់ព័ន្ធនឹង"បុគ្គលសំខាន់ៗនៅភ្នំពេញ និងសម្ព័ន្ធមិត្តយោធារបស់ពួកគេ" និងការធានា "អំពីការបោសសម្អាត" សន្និដ្ឋានថា "ការដឹកនាំរបស់ខ្មែរក្រហមអាចមិនមានស្ថេរភាព"[47] ។

22. សារទូរលេខតាមផ្លូវទូតអាមេរិកទីប្រាំមួយ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ និងមានចំណងជើងថា "ការសង្កេតរបស់អ្នកការទូតបរទេស ទៅលើការចោទប្រកាន់នៃការទម្លាក់គ្រាប់បែករបស់អាមេរិកនៅខេត្តសៀមរាប" ត្រូវបានធ្វើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងប៉ារីសទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៦" ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៨**)[48]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៦ នេះត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦ និងផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣។ ឯកសារនេះលើកឡើងអំពីដើមចមនៃការផ្ទុះគ្រាប់បែកដែលកើតមានឡើងនៅខេត្តសៀមរាប នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ពោលគឺ "ការទម្លាក់គ្រាប់បែកពីប្រទេសថៃ ដោយក្រុមកម្ពុជាដែលប្រឆាំង ការផ្ទុះកន្លែងស្តុកទុកគ្រាប់រំសេវដែលធ្វើឡើងដោយការវាយប្រហាររបស់ក្រុមឧទ្ទាម ឬដោយចៃដន្យ ឬ ដោយជម្លោះផ្ទៃក្នុងរបស់

[44] ដូចខាងលើ កថាខណ្ឌ ៣។

[45] ដូចខាងលើ កថាខណ្ឌ ២ក។

[46] ដូចខាងលើ កថាខណ្ឌ ៤ និង ១៧។

[47] ដូចខាងលើ សេចក្តីសង្ខេប និងកថាខណ្ឌ ៧ និង ១៦។

[48] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតប៉ារីស 'ការសង្កេតរបស់អ្នកការទូតបរទេសអំពីការចោទប្រកាន់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅសៀមរាប', ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦, PARIS 06963។

ក្រុមកុម្មុយនីស្ត ឬការទម្លាក់គ្រាប់បែកដោយវៀតណាមខាងត្បូង ឬដោយយន្តហោះវៀតណាម ដែលមានមូលដ្ឋាននៅប្រទេសឡាវ”[49]។

23. សារទូរលេខតាមផ្លូវទូតអាមេរិកទីប្រាំពីរ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦ និងមានចំណងជើងថា ឧបទ្ទវហេតុនៅខេត្តសៀមរាប៖ ខ្មែរសូវៀត” ត្រូវបានផ្ញើដោយទូតអាមេរិកប្រចាំនៅទីក្រុងបាងកក ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក (“សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៧” ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ៩**)[50]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៧ នេះត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦ និងបានផ្សព្វផ្សាយតាម WikiLeaks នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣។ ឯកសារនេះរាយការណ៍បន្តនូវការវិភាគរបស់សមាជិកមួយរូបនៃបុគ្គលិកស្ថានទូតសូវៀត ពាក់ព័ន្ធនឹងការផ្ទុះគ្រាប់បែកនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ នៅក្នុងខេត្តសៀមរាប ដែលសន្និដ្ឋានថា យន្តហោះប្រភេទ MiG 23 ដែលមានមូលដ្ឋាននៅប្រទេសចិន ឬវៀតណាម អាចមិនជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងការទម្លាក់គ្រាប់បែកនេះ[51]។ ទោះជាយ៉ាងនេះក្តី ម្ចាស់សារទូរលេខបានលើកឡើងអំពីលទ្ធភាព ដែលថាអាចជា យន្តហោះប្រភេទ MiG 23 ដែលមានមូលដ្ឋាននៅប្រទេសឡាវផ្នែកខាងត្បូងជាអ្នកទម្លាក់គ្រាប់បែកនោះ”[52]។

24. សារទូរលេខតាមផ្លូវទូតអាមេរិកទីប្រាំបី ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦ និងមានចំណងជើងថា “របាយការណ៍ស៊ុយអែតពាក់ព័ន្ធនឹងកម្ពុជា និងវៀតណាម” ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងប៉ារីស ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក (“សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៨” ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ១០**)[53]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៨ នេះត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦

---

[49] ដូចខាងលើ កថាខណ្ឌ ២។

[50] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតបាងកក, ‘ឧបទ្ទវហេតុនៅខេត្តសៀមរាប៖ ខ្មែរសូវៀត’, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦, BANGKO 05980។

[51] ដូចខាងលើ កថាខណ្ឌ ២។

[52] ដូចខាងលើ កថាខណ្ឌ ៣។

[53] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតប៉ារីស ‘របាយការណ៍ស៊ុយអែត ពាក់ព័ន្ធនឹងកម្ពុជា និង វៀតណាម’, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៧៦, PARIS 07801។

និងផ្សព្វផ្សាយដោយ WikiLeaks នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣។ ឯកសារនេះបានរាយការណ៍បន្តអំពីការវិភាគរបស់អ្នកការទូតស៊ុយអែតមួយរូប ពាក់ព័ន្ធនឹងការផ្ទុះគ្រាប់បែកនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ នៅខេត្តសៀមរាប ដែលសន្និដ្ឋានថា ការផ្ទុះគ្រាប់បែកនោះ"មិនមែនកើតឡើងថ្មីៗនេះទេ និងប្រហែលជាបណ្តាលមកពីជម្លោះផ្ទៃក្នុង"[54]។

25. សារទូរលេខតាមផ្លូវទូតអាមេរិកលេខប្រាំបួន ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ និងមានចំណងជើងថា "ព័ត៌មានជីវប្រវត្តិបន្ថែមសម្រាប់ ហោ ណាំហុង ដែលជារដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជា" ត្រូវបានផ្ញើដោយស្ថានទូតអាមេរិកប្រចាំទីក្រុងភ្នំពេញ ទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ("សារទូរលេខតាមផ្លូវទូតលេខ ៩" ភ្ជាប់មកជាមួយជា**ឯកសារសាធារណៈលេខ ១១**)[55]។ ហោ ណាំហុង ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបច្ចុប្បន្ន ត្រូវបានពិពណ៌នាថា "ជាមនុស្សឱកាសនិយមម្នាក់ ដែលខ្វះមូលដ្ឋានអំណាចផ្ទាល់ខ្លួន ប៉ុន្តែបានឡើងតំណែង ដោយការស្វះស្វែងចងសម្ព័ន្ធភាព និង ធ្វើផ្គាប់ចិត្តមេដឹកនាំដែលមានអំណាច [...]"[56]។ សារទូរលេខនេះរាយការណ៍បន្ត ដោយគូសបញ្ជាក់ថា ហោ ណាំហុង "បានក្លាយជាប្រធានជំរំបឹងត្របែក និង [...] ចូលរួមសហការក្នុងការសម្លាប់អ្នកទោសជាច្រើននាក់"[57]។

### *(i) សារទូរលេខតាមផ្លូវទូតរបស់អាមេរិកមិនអាចរកបាន នៅមុនពេលបើកការជំនុំជម្រះ*

26. អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ចាប់ផ្តើមឡើងនៅខែ មិថុនា ឆ្នាំ ២០១១[58]។ ទោះបីជាសារទូរលេខតាមផ្លូវទូតរបស់អាមេរិក ត្រូវបានផ្ញើចេញជាដំបូង

---

[54] ដូចខាងលើ កថាខណ្ឌ ២។

[55] សារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក ស្ថានទូតភ្នំពេញ, 'ជីវប្រវត្តិ៖ ព័ត៌មានជីវប្រវត្តិបន្ថែមសម្រាប់ ហោ ណាំហុង ដែលជារដ្ឋមន្ត្រីកិច្ចការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ', ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២, 02PHNOMPENH1361_a។

[56] ដូចខាងលើ កថាខណ្ឌ ១។

[57] ដូចខាងលើ កថាខណ្ឌ ២។

[58] **E307/1**, 'សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និង សេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)', ចុះថ្ងៃទី

*សំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកសារទូរលេខតាមផ្លូវទូតចំនួន ១១ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង*

នៅមុនកាលបរិច្ឆេទខាងលើយ៉ាងណាក្តី ក៏វាពុំមែនជាការសមហេតុសមផលទេ ដែលរំពឹងឱ្យមេធាវីការពារក្តីអាចកំណត់អត្តសញ្ញាណភស្តុតាងនេះ ឱ្យបាននៅមុនពេលបើកការជំនុំជម្រះ។

27. សារទូរលេខតាមផ្លូវទូតអាមេរិកពីលេខ ១ ដល់ ៤ នៅតែជាឯកសារសម្ងាត់ និងមិនអាចចូលមើលបាន រហូតដល់ពេលបណ្ណាសារដ្ឋានជាតិសហរដ្ឋអាមេរិកសម្រេចផ្សព្វផ្សាយវាជាសាធារណៈនៅក្នុងខែ មីនា ឆ្នាំ ២០១៤។ សារទូរលេខតាមផ្លូវទូតលេខ ៩ នេះត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់ និងមិនអាចចូលបើកមើលបានរហូតដល់ថ្ងៃដែលវាត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយ WikiLeaks នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១។ ដូច្នេះ សារទូរលេខតាមផ្លូវទូតទាំងនេះ មិនអាចរកបាននៅមុនថ្ងៃបើកការជំនុំជម្រះ និងអាចទទួលយកជាភស្តុតាងបានស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

28. សារទូរលេខតាមផ្លូវទូតពីលេខ ៥ និង ៦ ដល់ ៨ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈដោយបណ្ណាសារដ្ឋានជាតិសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៩ និង ក្នុងឆ្នាំ ២០០៦។ ប៉ុន្តែ ដោយសារពុំមានការបញ្ជាក់ថាព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈដោយបណ្ណាសារដ្ឋានជាតិសហរដ្ឋអាមេរិកនោះ វាពុំមែនជាការសមហេតុសមផលទេដែលរំពឹងឱ្យមេធាវីការពារក្តីអាចកំណត់អត្តសញ្ញាណភស្តុតាងនេះឱ្យបាននៅមុនពេលបើកការជំនុំជម្រះ។ មូលដ្ឋានផ្ទុកទិន្នន័យរបស់បណ្ណាសារដ្ឋានជាតិសហរដ្ឋអាមេរិក មានផ្ទុកកំណត់ហេតុជាអត្ថបទចំនួន ១០ ពាន់លានទំព័រ[59] និងមានសារទូរលេខផ្នែកការទូតរបស់សហរដ្ឋអាមេរិកជាង ២ លានឯកសារ ដែលទាក់ទងនឹងរយៈពេលដែលពាក់ព័ន្ធនោះ។ ដោយពិចារណាទៅលើភាពកម្រនៃប្រភពធនធាន ក្នុងការដែលមេធាវីការពារក្តីអាចរកបាន មេធាវីការពារក្តីពុំមានលទ្ធភាព និងពេលវេលា ហើយមិនគួររំពឹងឱ្យមេធាវីការពារក្តីមានពេលវេលា និងលទ្ធភាពដើម្បីស្រាវជ្រាវរកព័ត៌មាន ដែលអាចមានភាពពាក់ព័ន្ធនៅក្នុងចំណោមសម្ភារៈជាឯកសារដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះទេ។ មេធាវីការពារក្តីទើបតែដឹងថាមានសារទូរលេខតាមផ្លូវទូតទាំងនេះ នៅក្រោយការផ្សព្វផ្សាយវាដោយ WikiLeaks នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ និងថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣ តែប៉ុណ្ណោះ។ គ្រាន់តែបានទទួលព័ត៌មាននេះភ្លាម មេធាវីការពារក្តីបានចំណាយពេល និង

---

១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ **E307/1/2**, 'សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[59] *សូមមើល* http://www.archives.gov/publications/general-info-leaflets/1-about-archives.html។

ធនធានយ៉ាងច្រើន ដើម្បីស្រាវជ្រាវតាមរយៈឯកសារទាំងនោះ និងបានកំណត់ឃើញសារទូរលេខទាំងអស់នេះ។

29. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា សារទូរលេខតាមផ្លូវទូតដែលត្រូវធ្វើឡើង និងត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ នៅមុនពេលចាប់បើកការជំនុំជម្រះ និង នៅពេលក្រោយមកទៀតឯកសារនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធគេហទំព័រ WikiLeaks "មិនអាចរកបានពីមុនមក ទោះបីជាខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្តី"[60]។ ដូច្នេះ គ្មានហេតុផលណាមួយ ដែលត្រូវអនុវត្តឲ្យប្រាសចាកពីគោលការណ៍ដែលកំពុងអនុវត្តនៅក្នុងករណីបច្ចុប្បន្ននោះទេ។ ដូច្នេះ សារទូរលេខតាមផ្លូវទូតអាមេរិកពីលេខ ៥ ដល់ ៨ ត្រូវតែចាត់ទុកថាជាឯកសារដែលមិនអាចរកបាននៅមុនពេលបើកការជំនុំជម្រះ ទោះបីមេធាវីការពារក្តីខិតខំប្រឹងប្រែងសមហេតុផល ក្នុងការស្វែងរកឯកសារទាំងនោះយ៉ាងណាក្តី។ ដូច្នេះ សារទូរលេខតាមផ្លូវទូតទាំងនេះអាចទទួលយកជាភ័ស្តុតាងបាន ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

### *(ii) សារទូរលេខតាមផ្លូវទូតរបស់អាមេរិក ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២*

30. សារទូរលេខតាមផ្លូវទូតរបស់អាមេរិកមានផ្ទុកព័ត៌មានដែលពាក់ព័ន្ធនឹងអត្ថិភាព និងដើមចមនៃជម្លោះប្រដាប់អាវុធ ការបោសសម្អាតផ្ទៃក្នុង និង ស២១ រចនាសម្ព័ន្ធរដ្ឋបាល និងយោធា និងព្រមទាំងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា តាមទម្រង់នៃការទទួលខុសត្រូវជាច្រើន។

*អត្ថិភាព និងលក្ខណៈនៃជម្លោះប្រដាប់អាវុធ*

31. សារទូរលេខតាមផ្លូវការទូតរបស់អាមេរិកពីលេខ ១ ដល់ ៨ មានផ្ទុកព័ត៌មានពាក់ព័ន្ធនឹងទិដ្ឋភាពផ្សេងៗនៃជម្លោះប្រដាប់អាវុធ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ព័ត៌មានខាងក្រោមនេះ ពាក់ព័ន្ធនឹងផ្នែកមួយចំនួននៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងអត្ថិភាព និងលក្ខណៈនៃជម្លោះប្រដាប់អាវុធ[61]។ ឯកសារនេះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និងជាពិសេសពាក់ព័ន្ធនឹងផ្នែកទីប្រាំមួយ ("ស្តីអំពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ")[62]។

---

[60] *សូមមើល* កថាខណ្ឌ ១១ ខាងលើ។

[61] **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥០–១៥៥។

[62] *សូមមើល* **E315**, សេចក្តីសម្រេចស្តីពីលំដាប់លំដោយ កថាខណ្ឌ ១៤(ច)។

32. ជាដំបូង សារទូរលេខតាមផ្លូវទូតអាមេរិកផ្តល់នូវភ័ស្តុតាងអំពីការប្រឈមមុខដាក់គ្នាផ្ទាល់ រវាងកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំងប្រដាប់អាវុធវៀតណាម និង ភ័ស្តុតាងអំពីអន្តរាគមន៍ផ្នែកយោធារបស់កងកម្លាំងបរទេសមកលើទឹកដីកម្ពុជា។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ១ ពិពណ៌នាអំពី "សង្គ្រាមព្រំដែនជាមួយវៀតណាម" ពាក់ព័ន្ធនឹង "ការប្រយុទ្ធគ្នាយ៉ាងស្រួចស្រាល" រវាងកងទ័ពកម្ពុជា និងកងទ័ពវៀតណាម[63]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥ និយាយអំពីការវាយប្រហារដែលធ្វើឡើងដោយកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យនៅក្នុងទឹកដីវៀតណាម ដោយបន្ថែមថា ទីប្រឹក្សាយោធាចិនជាប់ពាក់ព័ន្ធក្នុងការរៀបចំផែនការសម្រាប់ប្រតិបត្តិការនេះ[64]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៦ និង ៧ បានសន្និដ្ឋានបន្ថែមទៀតថា យន្តហោះវៀតណាមដែលមានមូលដ្ឋាននៅប្រទេសវៀតណាម ឬ ឡាវ អាចជាប់ពាក់ព័ន្ធនឹងការទម្លាក់គ្រាប់បែកនៅខែ កុម្ភៈ ឆ្នាំ ១៩៧៦ នៅខេត្តសៀមរាប[65]។

33. ទីពីរ សារទូរលេខតាមផ្លូវទូតអាមេរិក ផ្តល់នូវភ័ស្តុតាងអំពីជម្លោះប្រដាប់អាវុធផ្ទៃក្នុង ពាក់ព័ន្ធម្យ៉ាងទៀតទៅនឹង ដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ រងការប្រឆាំងពី "ចលនាតស៊ូ" និង "ក្រុមប្រឆាំង"ខុសៗគ្នា។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ១ និយាយអំពីអត្ថិភាពនៃ "កម្លាំងតស៊ូ" ដឹកនាំដោយមេបញ្ជាការយោធាភូមិភាគបូព៌ា[66]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ២, ៣ និង ៤ និយាយអំពីឧបទ្ទវហេតុជាច្រើន ពាក់ព័ន្ធនឹងការលុកលុយចូលក្នុងទឹកដីកម្ពុជារបស់ក្រុមប្រដាប់អាវុធខ្មែរ ដែលមានមូលដ្ឋាននៅក្នុងប្រទេសថៃ[67]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥ ពិពណ៌នាបន្ថែមអំពីក្រុមប្រដាប់អាវុធដែលសកម្មនៅក្នុងទឹកដីកម្ពុជា និងបានពាក់ព័ន្ធក្នុងការប៉ះទង្គិចគ្នាជាប្រចាំជាមួយកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ[68]។ លើសពីនេះទៅទៀត សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៦ និង ៨ សន្និដ្ឋានថា ការផ្ទុះគ្រាប់បែកនៅខេត្តសៀមរាប នៅខែ កុម្ភៈ ឆ្នាំ ១៩៧៦ អាចបណ្តាលមកពីជម្លោះផ្ទៃក្នុង[69]។

---

[63] *សូមមើល* កថាខណ្ឌ ១៧ ខាងលើ។

[64] *សូមមើល* កថាខណ្ឌ ២១ ខាងលើ។

[65] *សូមមើល* កថាខណ្ឌ ២២-២៣ ខាងលើ។

[66] *សូមមើល* កថាខណ្ឌ ១៧ ខាងលើ។

[67] *សូមមើល* កថាខណ្ឌ ១៨-២០ ខាងលើ។

[68] *សូមមើល* កថាខណ្ឌ ២១ ខាងលើ។

[69] *សូមមើល* កថាខណ្ឌ ២២ និង ២៤ ខាងលើ។

34. ទីបី សារទូរលេខតាមផ្លូវទូតអាមេរិក ផ្តល់នូវភ័ស្តុតាងអំពីការជាប់ពាក់ព័ន្ធនៃប្រទេសជិតខាង នៅក្នុងផ្នែកខុសៗគ្នានៃជម្លោះផ្ទៃក្នុង។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ១ រាយការណ៍ថា "កម្លាំងតស៊ូ" នៅភូមិភាគបូព៌ា ត្រូវបានបណ្តុះបណ្តាល និងគាំទ្រដោយវៀតណាម[70]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៤ សន្និដ្ឋានថា វៀតណាមជ្រោមជ្រែងក្រុមប្រដាប់អាវុធកុម្មុនីស្តថៃនៅក្នុងប្រទេសកម្ពុជា[71]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥ គូសបញ្ជាក់ថា "ក្រុមតស៊ូ" ខ្មែរ ទទួលបានការជ្រោមជ្រែងពីយោធាថៃ និងបានទទួលហិរញ្ញប្បទានពីមន្ត្រីសាធារណៈជាន់ខ្ពស់របស់ថៃ[72]។

*ការបោសសម្អាតផ្ទៃក្នុង និង ស-២១*

35. ព័ត៌មានខាងលើទាក់ទងនឹងជម្លោះប្រដាប់អាវុធ គឺទាក់ទងផងដែរទៅនឹងការបោសសម្អាតផ្ទៃក្នុង[73] ដោយសារតែបុគ្គលត្រូវបានសង្ស័យថា មានទំនាក់ទំនងជាមួយសត្រូវត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស២១។ ទំនាក់ទំនងរវាងជម្លោះ និងការបោសសម្អាតផ្ទៃក្នុងត្រូវបានលើកឡើងនៅក្នុងសារទូរលេខតាមផ្លូវទូតអាមេរិកលេខ ១ ដែលភ្ជាប់ "ការបោសសម្អាត" ទៅនឹង "អស្ថេរភាព" បណ្តាលមកពីការបះបោរ និងមេបញ្ហាការតំបន់ ជាពិសេសគឺ "ក្រុមតស៊ូដែលគាំទ្រដោយក្រុងហាណូយ"[74]។ ដូចគ្នានេះដែរសារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៥ លើកឡើងអំពី "ការបោសសម្អាត" ធ្វើឡើងបន្ទាប់ពីមានការប៉ុនប៉ងធ្វើរដ្ឋប្រហារ[75]។ ព័ត៌មាននេះគឺទាក់ទងនឹងផ្នែកទី៤ នៃសំណុំរឿង ០០២/០២ ("ការបោសសម្អាតផ្ទៃក្នុង និង មន្ទីរសន្តិសុខ")[76]។

*វចនាសម្ព័ន្ធរដ្ឋបាល និងយោធា*

36. លើសពីនេះទៅទៀត សេចក្តីយោងជាច្រើននៅក្នុងសារទូរលេខតាមផ្លូវទូតអាមេរិកពីលេខ ១ ដល់

---

[70] *សូមមើល* កថាខណ្ឌ ១៧ ខាងលើ។

[71] *សូមមើល* កថាខណ្ឌ ២០ ខាងលើ។

[72] *សូមមើល* កថាខណ្ឌ ២១ ខាងលើ។

[73] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៩២ ដល់ ២០៣ និង ៤១៥ ដល់ ៤៣៤។

[74] សូមមើល កថាខណ្ឌ ១៧ ខាងលើ។

[75] សូមមើល កថាខណ្ឌ ២១ ខាងលើ។

[76] សូមមើល **E315** "សេចក្តីសម្រេចលើលំដាប់លំដោយ" កថាខណ្ឌ ១៤ (ឃ)(គ)។

៦ និង ៨ និយាយអំពី "ជម្លោះផ្ទៃក្នុង" "ការផ្ដាច់ខ្លួន" "អស្ថេរភាព" "ការតស៊ូដណ្ដើមតំណែងដឹកនាំ" និង "ការបះបោរប្រឆាំង" នៅក្នុង ប.ក.ក[77]។ សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៩ និយាយបន្ថែមអំពី ហោ ណាំហុង ដែលជាអតីតមេមន្ទីរសន្ដិសុខបឹងត្របែក[78] ដែលត្រូវបានលើកឡើងយ៉ាងច្រើននៅក្នុងដីកាដំណោះស្រាយ[79]។ ព័ត៌មាននេះពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងយោធា[80] ដូច្នេះវាពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ទាំងមូល។

*ទម្រង់នៃការទទួលខុសត្រូវ*

37. នៅទីបញ្ចប់ សេចក្ដីយោងជាច្រើននៅក្នុងសារទូរលេខតាមផ្លូវទូតអាមេរិកពីលេខ ១ ដល់ ៦ និង ៨ និយាយអំពី "ជម្លោះផ្ទៃក្នុង" "ការផ្ដាច់ខ្លួន" "អស្ថេរភាព" "ការតស៊ូដណ្ដើមតំណែងដឹកនាំ" និង "ការបះបោរប្រឆាំង" នៅក្នុង ប.ក.ក[81] ពាក់ព័ន្ធទៅនឹងសមាភាពនៃការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួម[82] និងការចោទប្រកាន់អំពីអំណាច និងការគ្រប់គ្រងរបស់ នួន ជា ទៅលើកម្មាភិបាល ប.ក.ក[83] និងការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់គាត់ក្នុងការបញ្ជា[84] ញុះញង់[85] និងក្នុងនាមជាថ្នាក់លើមួយរូប[86]។ ព័ត៌មាននេះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ទាំងមូល និងជាពិសេសពាក់ព័ន្ធនឹងផ្នែកចុងក្រោយ ("ស្ដីអំពីតួនាទីជនជាប់ចោទ")[87]។

## *(iii)* ***សារទូរលេខតាមផ្លូវទូតរបស់អាមេរិកអាចជឿជាក់បាន***

38. សារទូរលេខតាមផ្លូវទូតអាមេរិកពីលេខ ១ ដល់ ៨ ត្រូវបានទាញចេញពីគេហទំព័រផ្លូវការរបស់

---

[77] *សូមមើល* កថាខណ្ឌ ១៧-២២ និង ២៤ ខាងលើ។

[78] *សូមមើល* កថាខណ្ឌ ២៥ ខាងលើ។

[79] **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៧, ១០៩៦, ១១០១–១១០៤, និងកថាខណ្ឌផ្សេងទៀត។

[80] ដូចខាលើ កថាខណ្ឌ ៣៣–៦៣ និង ១១៣–១៤៩។

[81] *សូមមើល* កថាខណ្ឌ ១៧–២២ និង ២៤ ខាងលើ។

[82] **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥៩ និង ១៥២៩។

[83] ដូចខាងលើ កថាខណ្ឌ ៨៧០, ៨៧៦, ៨៨០, ៨៨១, ៨៨២, ៨៨៤, ៨៩១, ៩១៣, ៩៦០, ១៥៣២, និងកថាខណ្ឌផ្សេងទៀត។

[84] ដូចខាងលើ កថាខណ្ឌ ១៥៥៣–១៥៥៤។

[85] ដូចខាងលើ កថាខណ្ឌ ១៥៤៧–១៥៤៨។

[86] ដូចខាងលើ កថាខណ្ឌ ១៥៥៨–១៥៦០។

[87] *សូមមើល* **E315**, សេចក្ដីសម្រេចស្ដីពីលំដាប់លំដោយ, កថាខណ្ឌ ១៤(ធ)។

រដ្ឋបាលនៃបណ្ណាសារដ្ឋានជាតិ និងកំណត់ហេតុរបស់សហរដ្ឋអាមេរិក និងយថាភាពរបស់វាគឺមានលក្ខណៈច្បាស់លាស់។

39. សារទូរលេខតាមផ្លូវទូតអាមេរិកលេខ ៩ ក៏អាចជឿជាក់បានមិនតិចជាងនេះដែរ។ ព័ត៌មានដែលមាននៅក្នុងឯកសារនេះ ត្រូវបានបញ្ជាក់ដោយភ័ស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង។ ដីកាដំណោះស្រាយផ្អែកលើចម្លើយដែលសរសេរផ្ទាល់ដៃរបស់ ហោ ណាំហុង បញ្ជាក់ថា គាត់មានវត្តមាននៅបឹងត្របែក[88]។ ជីវប្រវត្តិរបស់ ហោ ណាំហុង ពីកំណត់ហេតុផ្លូវការរបស់សេវាសន្តិសុខរដ្ឋនៃអតីតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ក៏បានបញ្ជាក់ផងដែរថា គាត់ជា"មេដឹកនាំ"នៃជំរំបឹងត្របែក (*'Leiter des Lagers'*) និង ជា "ជំនួយការ" (*'Helfershelfer Ieng Sarys'*) របស់ អៀង សារី៖

> បញ្ជូនទៅបឹងត្របែក ខាងត្បូងភ្នំពេញ [...] ហ.ណ ហុង គឺជាមេដឹកនាំជំរុំ និងជាអ្នកទោសដូចអ្នកផ្សេងដែរ។ ក៏ប៉ុន្តែការងារគាត់គឺស្រួលជាងគេ និងមានពេលមួយក្នុងពេលពេលដែលចុះមកពិនិត្យដោយ អៀង សារី គាត់អាចរៀបរាប់អំពីស្ថានភាពនៅក្នុងជំរុំ។ [កោសលុប] ស្តីបន្ទោស ហុង ថាជាជំនួយការរបស់ អៀង សារី[89]។

## IV- ដំណោះស្រាយដែលស្នើសុំ

40. អាស្រ័យដូចបានរៀបរាប់ក្នុងសំអាងហេតុខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសារទូរលេខតាមផ្លូវទូតទាំងនេះ ជាភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២។

**សហមេធាវីការពារក្តីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**

---

[88] **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ១០៨៧ និង ១០៩៩។

[89] **E307/5.2.8**, 'កម្រងជីវប្រវត្តិខ្លីៗចំនួន ២០ ពីបណ្ណាសារដ្ឋាន Stasi– ជីវប្រវត្តិ ហោ ណាំហុង', ERN 01002022 (បកប្រែដោយបុគ្គលិកខាងក្នុងការិយាល័យរបស់មេធាវីការពារក្តី)។ (ភាសាដើមជាភាសាអាល្លឺម៉ង់ដូចនេះ *'Verlegung nach Beng Trabek im Süden von Phnom Penh [...]. H. N. Hong ist als Leiter des Lagers genauso Häftling wie die anderen. Er hat es aber leichter und kann bei von Ieng Sary durchgeführten Kontrollbesuchen die Situation im Lager darlegen. [Redacted] beschuldigte Hong, ein Helfershelfer Ieng Sarys zu sein'*)។